ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ០១៥៥/១៤.នក.ប្រក

# ប្រកាស
## ស្តីពី
## ការប្រគល់សិទ្ធិជូនមន្ទីររ៉ែ និងថាមពលរាជធានី ខេត្ត ក្នុងការពិនិត្យ សម្រេច និងផ្តល់អាជ្ញាបណ្ណសិប្បកម្មធនធានរ៉ែ

## រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពី ការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ
- បានឃើញអនុក្រឹត្យលេខ ៥៧៦ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែនិងថាមពល

ព្រះរាជាណាចក្រកម្ពុជា ក្រសួងរ៉ែ និង ថាមពល

# សម្រេច

**ប្រការ១ ..**

ត្រូវបានប្រគល់សិទ្ធិជូនដល់មន្ទីររ៉ែនិងថាមពលរាជធានី ខេត្ត ក្នុងការពិនិត្យ សម្រេច និងផ្ដល់អាជ្ញាបណ្ណសិប្បកម្មធនធានរ៉ែ ជូនដល់ប្រជាពលរដ្ឋខ្មែរដែលមានបំណងធ្វើអាជីវកម្មធនធានរ៉ែមានលក្ខណៈជាសិប្បកម្ម។

**ប្រការ២ ..**

មន្ទីររ៉ែនិងថាមពលរាជធានី ខេត្ត ត្រូវចុះបញ្ជីទទួលពាក្យស្នើសុំអាជ្ញាបណ្ណសិប្បកម្មធនធានរ៉ែ នៅពេលដែលពិនិត្យឃើញថា សំណុំលិខិតស្នើសុំនោះមានភាពត្រឹមត្រូវ និងគ្រប់គ្រាន់។

សំណុំលិខិតស្នើសុំអាជ្ញាបណ្ណសិប្បកម្មធនធានរ៉ែ ត្រូវបំពេញតាមបែបបទ និងនីតិវិធីដែលកំណត់ដោយក្រសួងរ៉ែនិងថាមពល។ ទីតាំងស្នើសុំធ្វើអាជីវកម្មធនធានរ៉ែមានលក្ខណៈជាសិប្បកម្មត្រូវមានការបញ្ជាក់ឯកភាពពីអាជ្ញាធរស្រុក ខណ្ឌដែលទីតាំងនោះស្ថិតនៅ។

**ប្រការ៣ ..**

មន្ទីររ៉ែនិងថាមពលរាជធានី ខេត្ត ត្រូវចុះអង្កេតពិនិត្យ និងវាយតម្លៃដល់ទីកន្លែងស្នើសុំធ្វើសិប្បកម្មធនធានរ៉ែក្នុងរយៈពេល ១០ (ដប់)ថ្ងៃយ៉ាងយូរ ក្រោយពីបានចុះបញ្ជីទទួលពាក្យស្នើសុំអាជ្ញាបណ្ណសិប្បកម្មធនធានរ៉ែ ហើយត្រូវធ្វើរបាយការណ៍ស្ដីពី លទ្ធផលនៃការចុះអង្កេតពិនិត្យ និងវាយតម្លៃ ដោយមានការសន្និដ្ឋានច្បាស់លាស់លើទិដ្ឋភាពបរិស្ថាន សង្គម សេដ្ឋកិច្ច និងបច្ចេកទេស សម្រាប់ជាមូលដ្ឋានក្នុងការសម្រេចផ្ដល់អាជ្ញាបណ្ណសិប្បកម្មធនធានរ៉ែ។

**ប្រការ៤ ..**

មន្ទីររ៉ែនិងថាមពលរាជធានី ខេត្ត ត្រូវដាក់សំណុំលិខិតស្នើសុំអាជ្ញាបណ្ណសិប្បកម្មធនធានរ៉ែជូនទៅអភិបាលនៃគណៈអភិបាលរាជធានី ខេត្តដើម្បីស្នើសុំការឯកភាពជាគោលការណ៍។ ក្នុងករណីមន្ទីររ៉ែនិងថាមពលរាជធានី ខេត្ត មិនឯកភាពលើសំណើសុំនោះ មន្ទីរត្រូវធ្វើការឆ្លើយតបជាលាយលក្ខណ៍អក្សរទៅអ្នកស្នើសុំស្ដីពីការបដិសេធក្នុងការផ្ដល់អាជ្ញាបណ្ណសិប្បកម្ម ដោយមិនចាំបាច់ធ្វើការបញ្ជូនសំណុំលិខិតស្នើសុំនោះទៅអភិបាលនៃគណៈអភិបាលរាជធានី ខេត្តឡើយ។

ក្រោយពីទទួលបានការឯកភាពជាគោលការណ៍ពីអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត រួចហើយ មន្ទីររ៉ែនិងថាមពលរាជធានី ខេត្ត ត្រូវផ្ដល់នូវអាជ្ញាបណ្ណសិប្បកម្មធនធានរ៉ែជូនដល់អ្នកស្នើសុំក្នុងរយៈពេលយ៉ាងយូរ ៣ (បី)ថ្ងៃ។ ក្នុងករណីអភិបាលនៃគណៈអភិបាលរាជធានី ខេត្តមិនឯកភាពលើការស្នើសុំអាជ្ញាបណ្ណសិប្បកម្ម

ធនធានរ៉ែនោះទេ មន្ទីររ៉ែនិងថាមពលរាជធានី ខេត្តត្រូវធ្វើរបាយការណ៍ជូនក្រសួងរ៉ែនិងថាមពល ដើម្បីស្នើសុំការសម្រេចលើការស្នើសុំអាជ្ញាបណ្ណសិប្បកម្មធនធានរ៉ែនោះ។ ក្រោយពីទទួលបានការសម្រេចពីក្រសួងរ៉ែនិងថាមពល មន្ទីររ៉ែនិងថាមពលរាជធានី ខេត្ត ត្រូវធ្វើការឆ្លើយតបជាលាយលក្ខណ៍អក្សរទៅអ្នកស្នើសុំអំពីការសម្រេចនោះ។

**ប្រការ៥ ..**

មន្ទីររ៉ែនិងថាមពលរាជធានី ខេត្ត ត្រូវធ្វើការត្រួតពិនិត្យសកម្មភាពអាជីវកម្មសិប្បកម្មធនធានរ៉ែជាប្រចាំ ដើម្បីធានាឲ្យការធ្វើអាជីវកម្មបានត្រឹមត្រូវតាមបច្ចេកទេស និងធានានូវការប្រមូលចំណូលជូនរដ្ឋ។

**ប្រការ៦ ..**

មន្ទីររ៉ែនិងថាមពលរាជធានី ខេត្ត ត្រូវធ្វើរបាយការណ៍ប្រចាំខែជូនក្រសួងរ៉ែនិងថាមពលស្តីពី ការផ្តល់អាជ្ញាបណ្ណសិប្បកម្មធនធានរ៉ែ ការបដិសេធក្នុងការផ្តល់អាជ្ញាបណ្ណសិប្បកម្មធនធានរ៉ែ និងការត្រួតពិនិត្យសកម្មភាពអាជីវកម្មសិប្បកម្មធនធានរ៉ែ ដោយមានភ្ជាប់មកជាមួយនូវច្បាប់ចម្លងអាជ្ញាបណ្ណសិប្បកម្មធនធានរ៉ែ របាយកាណ៍អង្កេតពិនិត្យវាយតម្លៃ និងឯកសារចាំបាច់នានា។

**ប្រការ៧ ..**

អគ្គនាយកនៃអគ្គនាយកដ្ឋានធនធានរ៉ែ អគ្គាធិការ ប្រធានមន្ទីររ៉ែនិងថាមពលរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ២០១៥

រដ្ឋមន្ត្រី

ស៊ុយ សែម

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់សាលារាជធានី ខេត្ត
- ដូចប្រការ៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ